OFFICE OF FILM
& LITERATURE
CLASSIFICATION
*Te Tari Whakarōpū Tukuata, Tuhituhinga*

# ការចាត់ថ្នាក់ខ្សែភាពយន្ត វីដេអូ នឹងការបោះពុម្ពផ្សាយនៅញូហ្ស៊ីលែន

សូមអរគុណដែលបានមើលព័ត៌មានអំពីការចាត់ថ្នាក់ខ្សែភាពយន្ត វីដេអូ នឹងការបោះពុម្ពផ្សាយជា ភាសាខ្មែរ។ យើងសង្ឃឹមថា ព័ត៌មាននេះនឹងឆ្លើយសំនួរផ្សេងៗរបស់លោកអ្នកអំពីការចាត់ថ្នាក់ ខ្សែភាពយន្ត វីដេអូ និងការបោះពុម្ពផ្សាយនៅញូហ្ស៊ីលែន។

បើលោកអ្នកមានសំនួរផ្សេងៗអំពីការចាត់ថ្នាក់កម្មវិធីទូរទស្សន៍និងវិទ្យុ សូមមើលវ៉ិបសាយ *អាជ្ញាធរបទដ្ឋានការផ្សាយ* (Broadcasting Standards Authority) - www.bas.govt.nz ។

**ច្បាប់ខាងចាត់ថ្នាក់ខ្សែភាពយន្ត វីដេអូ និងការបោះពុម្ពផ្សាយរបស់ញូហ្ស៊ីលែនឈ្មោះ *ច្បាប់ឆ្នាំ១៩៩៣ ស្តីពីការចាត់ថ្នាក់ខ្សែភាពយន្ត វីដេអូ និងការបោះពុម្ពផ្សាយ (THE FILMS, VIDEOS AND PUBLICATIONS CLASSIFICATION ACT 1993)*។**

ច្បាប់នេះអនុញ្ញាតឲ្យ *ការិយាល័យចាត់ថ្នាក់ខ្សែភាពយន្តនិងអក្សរសាស្ត្រ* (Office of Film and Literature Classification) ចាត់ថ្នាក់វត្ថុដូចជាខ្សែភាពយន្ត ឌីវីឌី សៀវភៅមើល វីដេអូល្បែងកំសាន្ត ទស្សនាវដ្តី និងឯកសារកុំព្យូទ័រ។ នៅញូហ្ស៊ីលែនដើម្បីដាក់លក់  ដាក់ជួល ឬដាក់តាំងឲ្យមើលបាន ខ្សែភាពយន្តត្រូវតែមានផ្លាកចាត់ថ្នាក់ញូហ្ស៊ីលែនជាផ្លូវការ។ វីដេអូល្បែងកំសាន្តដែលមានការកំរិត តាមអាយុ ចាំបាច់ត្រូវតែមានផ្លាកចាត់ថ្នាក់ញូហ្ស៊ីលែនជាផ្លូវការដើម្បីដាក់លក់  ដាក់ជួល ឬដាក់ តាំងឲ្យមើលនៅញូហ្ស៊ីលែនបាន។

## តើច្បាប់ចាត់ថ្នាក់ប៉ះពាល់លោកអ្នក និងគ្រួសារលោកអ្នកយ៉ាងណា

នៅញូហ្ស៊ីលែនច្បាប់ចាត់ថ្នាក់ភាពយន្ត វីដេអូ នឹងការបោះពុម្ពផ្សាយ ជួយការពារគ្រួសារលោកអ្នក អំពីវត្ថុដែលឲ្យមានទុក្ខសោក។

### អ្វីៗដែលលោកអ្នកត្រូវដឹងអំពីច្បាប់ចាត់ថ្នាក់ខ្សែភាពយន្ត វីដេអូ និងការបោះពុម្ពផ្សាយ

- ការផ្តល់ឌីវីឌី វីដេអូល្បែងកំសាន្ត សៀវភៅមើល ទស្សនាវដ្តី និង ឯកសារកុំព្យូទ័រដែលមាន ការកំរិតតាមអាយុ ទៅមនុស្សអាយុក្រោមកំរិតនៅលើផ្លាកចាត់ថ្នាក់ជាអំពើ ខុសច្បាប់។
- ការផ្តល់ឌីវីឌី វិដេអូល្បែងកំសាន្ត សៀវភៅមើល ទស្សនាវដ្តី និង ឯកសារកុំព្យូទ័រដែលមាន ការកំរិតតាមអាយុ ទៅក្មេងៗ ជាអំពើខុសច្បាប់ សូម្បីតែវត្ថុដែលមានការកំរិតតាមអាយុ ទាំងនោះមិនមានផ្លាកចាត់ថ្នាក់កំរិតអាយុក៏ដោយ។
- ការផ្តល់ឌីវីឌី វិដេអូល្បែងកំសាន្ត សៀវភៅមើល ទស្សនាវដ្តី និង ឯកសារកុំព្យូទ័រដែលមាន ការរួមរ័ក្សដ៏ជាក់ស្តែង ទៅមនុស្សអាយុក្រោម១៨ឆ្នាំ ជាអំពើខុសច្បាប់។

សូមមើល*មាតិកាកំរិតតាមអាយុ* ខាងក្រោមដើម្បីដឹងព័ត៌មានអំពីប្រភេទមាតិកាដែលអាចដាក់កំរិត តាមអាយុ។

## ផ្លាកចាត់ថ្នាក់ពណ៌ក្រហមជាការកំរិតតាមអាយុជាផ្លូវការ

ពណ៌នៃផ្លាកចាត់ថ្នាក់គឺដូចភ្លើងចរាចរ៖

- **បៃតង**មានន័យថាអ្នកណាមួយក៏អាចមើលខ្សែភាពយន្តនេះបាន។
- **លឿង**មានន័យថាអ្នកណាមួយក៏អាចមើលបាន, ក៏ប៉ុន្តែខ្សែភាពយន្តនេះប្រហែលជាមិន សមម្យត្រឹមត្រូចំពោះទស្សនិកជនខ្លះៗ។
- **ក្រហម**មានន័យថាខ្សែភាពយន្តនោះមានការកំរិតតាមអាយុជាផ្លូវការ។ លោកអ្នកមិនអាច បញ្ចាំងខ្សែភាពយន្តនោះឲ្យមនុស្សដែលមានអាយុតិចជាងអាយុនៅលើផ្លាកចាត់ថ្នាក់ទេ។

ការពណ៌នានៅលើផ្លាកចាត់ថ្នាក់ ដែលប្រាប់អ្នកអំពីមាតិកានៅក្នុងខ្សែភាពយន្តមួយ។ មាតិកា នេះប្រហែលនឹងអាចធ្វើឲ្យអ្នកខ្លះអាក់អន់ ឬប្រកាន់ឃើសចិត្ត។

## ផ្លាកចាត់ថ្នាក់




G – ខ្សែភាពយន្តនេះសមរម្យត្រឹមត្រូវសំរាប់មនុស្សគ្រប់ៗគ្នា។




PG – អ្នកណាម្នាក់ក៏អាចមើលខ្សែភាពយន្តនេះបាន។ បើក្មេងៗមើលខ្សែភាពយន្តនេះ គួរតែមាន ឳពុកម្តាយ ឬអ្នកទទួលខុសត្រូវពេញវ័យម្នាក់ជាអ្នកឲ្យសេចក្តីណែនាំ។




M – អ្នកណាម្នាក់ក៏អាចមើលខ្សែភាពយន្តនេះបាន។ តែខ្សែភាពយន្តនេះសមរម្យត្រឹមត្រូវជាង ចំពោះមនុស្សអាយុលើស១៦ឆ្នាំ។




RP13 – បញ្ចាំងខ្សែភាពយន្តនេះឲ្យក្មេងអាយុក្រោម១៣ឆ្នាំ គឺខុសច្បាប់ លើកលែងតែពួកគេមាន មនុស្សទទួលខុសត្រូវពេញវ័យម្នាក់ដែលទៅមើលជាមួយ។




RP16 – បញ្ចាំងខ្សែភាពយន្តនេះឲ្យក្មេងអាយុក្រោម១៦ឆ្នាំគឺខុសច្បាប់ លើកលែងតែពួកគេមាន មនុស្សទទួលខុសត្រូវពេញវ័យម្នាក់ដែលទៅមើលជាមួយ។




R13 – បញ្ចាំងខ្សែភាពយន្តនេះឲ្យក្មេងអាយុក្រោម១៣ឆ្នាំមើល គឺខុសច្បាប់។




R15 – បញ្ចាំងខ្សែភាពយន្តនេះឲ្យក្មេងអាយុក្រោម១៥ឆ្នាំមើល គឺខុសច្បាប់។




R16 – បញ្ចាំងខ្សែភាពយន្តនេះឲ្យក្មេងអាយុក្រោម១៦ឆ្នាំមើល គឺខុសច្បាប់។




R18 – បញ្ចាំងខ្សែភាពយន្តនេះឲ្យក្មេងអាយុក្រោម១៨ឆ្នាំមើល គឺខុសច្បាប់។

### ការលក់ឌីវីឌី

លោកអ្នកត្រូវមានផ្លាកចាត់ថ្នាក់សំរាប់ឌីវីឌី បើលោកអ្នកចង់លក់ឌីវីឌីរបស់លោកអ្នកនៅក្នុងប្រទេស ញូហ្ស៊ីលែន។ គេនឹងអាចផាកពិន័យលោកអ្នកដល់ទៅ៣ពាន់ដុល្លារ បើលោកអ្នកលក់ឌីវីឌី ដែលមិនមានផ្លាកចាត់ថ្នាក់ញូហ្ស៊ីលែននោះទេ។

## វត្ថុកំរិតតាមអាយុ ឬវត្ថុខុសច្បាប់

### មាតិកាកំរិតតាមអាយុ

មាតិកាដែលអាចមានកំរិតតាមអាយុមានរួមទាំង៖

- ការរួមរ័ក្ស
- សេចក្តីភយ័រន្ធត់
- បទឧក្រិដ្ឋ ឬអកប្បកិរិយាដែលអាចបណ្តាលអោយមានគ្រោះថ្នាក់
- អំពើកាចកម្រោលបំពាន
- អំពើសាហាវឃោរឃៅ
- ភាសាសម្តីដែលធ្វើឱ្យឈឺចិត្តខ្លាំង
- អត្តឃាដកម្ម ឬការធ្វើខ្លួនឯងឱ្យមានរបួសឈឺចាប់ផ្លូវកាយ

### មាតិកាខុសច្បាប់

មាតិកាមួយចំនួនគឺតែងតែខុសច្បាប់ជាដារាបនៅប្រទេសញូហ្ស៊ីលែន៖

- មាតិការួមរ័ក្សដែលមានជាប់ទាក់ទងក្មេង
- មាតិកាដែលលើកទឹកចិត្តការរួមរ័ក្សដែលពោរពេញដោយអំពើសាហាវឃោរឃៅនឹងការ រួមរ័ក្សដែលមានការបង្ខិតបង្ខំ
- មាតិកាដែលលើកទឹកចិត្តអំពើទារុណកម្ម ឬអំពើសាហាវឃោរឃៅដ៏ខ្លាំងបំផុត
- មាតិកាខាងរួមរ័ក្សដែលមានជាប់ទាក់ទងសត្វធាតុ
- មាតិកាខាងរួមរ័ក្សដែលមានជាប់ទាក់ទងសាកសព
- មាតិកាខាងរួមរ័ក្សដែលមានជាប់ទាក់ទងទឹកម៉ូត្រ ឬលាមក

មាតិកាខ្លះទៀតក៏អាចខុសច្បាប់នៅញូហ្ស៊ីលែនដែរ។ នេះមានរួមទាំងមាតិកាដែល៖

- លើកទឹកចិត្តអកប្បកិរិយាឧក្រិដ្ឋ
- លើកទឹកចិត្តអំពើសាហាវឃោរឃៅ
- លើកទឹកចិត្តការរលោភក្មេងខាងការរួមរ័ក្ស
- កេងប្រវ័ញ្ចយកផលប្រយោជន៍ពីភាពអាក្រាតរបស់ក្មេង
- លើកទឹកចិត្តអកប្បកិរិយាមើលថោក និងប្រកាន់ពីសអើង

### ការមានជារបស់ខ្លួននូវវត្ថុមិនត្រឹមត្រូវតាមច្បាប់ ជាបទឧក្រិដ្ឋ

មានជារបស់ខ្លួន ឬទាញយកពីអ៊ិនធើនែត ឬលក់ចែកចាយវត្ថុមិនត្រឹមត្រូវតាមច្បាប់ គឺជាបទ ឧក្រិដ្ឋ។ លោកអ្នកនឹងអាចចូលពន្ធនាគារមានរយៈរហូតដល់១០ឆ្នាំ បើលោកអ្នកមានជារបស់ខ្លួន បានទាញយកពីអ៊ិនធើនែត ឬលក់ចែកចាយវត្ថុមិនត្រឹមត្រូវតាមច្បាប់។ សូមមើល *មាតិកាដែលល្មើសច្បាប់* ខាងលើដើម្បីយកព័ត៌មានអំពីជំពូកមាតិកាដែលខុសច្បាប់។

# ប្រពន្ធ័ចាត់ថ្នាក់ខ្សែភាពយន្ត វីដេអូ និងការបោះពុម្ពផ្សាយនៅញូហ្ស៊ីឡែន

**មានអង្គការជាច្រើនដែលទទួលខុសត្រូវចាត់ថ្នាក់ថ្នាក់ខ្សែភាពយន្ត វីដេអូ និងការ បោះពុម្ពផ្សាយនៅញូហ្ស៊ីឡែន**

**ការិយាល័យចាត់ថ្នាក់ខ្សែភាពយន្ត និងអក្សរសាស្ត្រ (Office of Film and Literature Classification)**

- យើងជាអង្គការឯករាជ្យមួយរបស់រដ្ឋាភិបាល។
- *ប្រធានការចាត់ថ្នាក់* (Chief Censor) *ជាចាងហ្វាងការិយាល័យចាត់ថ្នាក់ខ្សែភាពយន្ត និងអក្សរសាស្ត្រ ។*
- យើងចាត់ថ្នាក់វត្ថុដែលអាចកំរិតអាយុ ឬវត្ថុហាមតែម្តង។ របស់មួយអាចត្រូវ កំរិតតាមអាយុឬហាមបើមានការរួមរ័ក្ស គួរអោយភ័យរន្ធត់ បទឧក្រិដ្ឋ អំពើកម្រោលបំពាន សាហាវឃោរឃៅ ឬភាសាសម្តីដែលធ្វើឲ្យឈឺចិត្តខ្លាំង។
- យើងចាត់ថ្នាក់ខ្សែភាពយន្ត ឌីវីឌីនិង វិដេអូល្បែងកំសាន្តដែលត្រូវកំរិតតាម អាយុទាំងអស់ នៅញូហ្ស៊ីឡែន។
- យើងក៏អាចចាត់ថ្នាក់សៀវភៅមើល ទស្សនាវដ្តី ឯកសារកុំព្យូទ័រ និងអ្វីៗទៀតផងដែរ។

ការិយាល័យចាត់ថ្នាក់ខ្សែភាពយន្ត និងអក្សរសាស្ត្រ ក៏ឆ្លើយទៅសំនួរ និងបណ្តឹង តវាពី សាធារណជនដែរ។
យើងធ្វើការស្រាវជ្រាវអំពីបញ្ហាផ្សេងៗនៃការចាត់ថ្នាក់។ យើងក៏ផ្តល់ឱវាទ ព័ត៍មាន និងធនធានផ្សេងៗអំពីការចាត់ថ្នាក់ដោយឥតយកថ្លៃផងដែរ។

សាធារណជនអាចសាកសួរ*ការិយាល័យចាត់ថ្នាក់ខ្សែភាពយន្តនិងអក្សរសាស្ត្រ* ដើម្បីចាត់ថ្នាក់ អ្វីមួយ, ដូចជាសៀវភៅមើល ឬទស្សនាវត្តីមួយក្បាល។ សូមមើលទំនាក់ទំនង *ការិយាល័យចាត់ថ្នាក់ខ្សែភាពយន្ត និងអក្សរសាស្ត្រ* ខាងក្រោមដើម្បីយកព័ត៍មាន អំពីការយករបស់អ្វីមួយទៅចាត់ថ្នាក់។

**អង្គការខាងដាក់ផ្លាកចាត់ថ្នាក់ខ្សែភាពយន្ត និង វីដេអូ (Film and Video Labelling Body)**

- ចាត់ថ្នាក់ខ្សែភាពយន្ត ឌីវីឌី និងវីដេអូល្បែងកំសាន្តដែលមិនកំរិតតាមអាយុ។
- ផ្តល់ផ្លាកចាត់ថ្នាក់សំរាប់ ខ្សែភាពយន្ត និងឌីវីឌីទាំងអស់។

**_នគរបាល_ (POLICE) _គយ_ (CUSTOMS) និង _ក្រសួងការក្នុងប្រទេស_ (DEPARTMENT OF INTERNAL AFFAIRS) ធ្វើឱយប្រតិបត្តិ ច្បាប់ខាងការចាត់ថ្នាក់ខ្សែភាពយន្ត វីដេអូ និងការ បោះពុម្ពផ្សាយនៅញូហ្ស៊ីឡែន**

**ក្រសួងការក្នុងប្រទេស (Department of Internal Affairs)**

*អង្គភាពប្រព្រឹត្តខាងការចាត់ថ្នាក់* (Censorship Compliance Unit) នៃ *ក្រសួងការក្នុងប្រទេស* គឺជាអង្គការចម្បងដែលធ្វើឱយប្រតិបត្តិ ច្បាប់ខាងការចាត់ថ្នាក់ខ្សែភាពយន្ត វីដេអូ និងការបោះពុម្ព ផ្សាយនៅញូហ្ស៊ីឡែន។ *អង្គភាពប្រព្រឹត្តខាងការចាត់ថ្នាក់* ធ្វើឱយប្រតិបត្តិនូវការចាត់ថ្នាក់ដែល បានសំរេចដោយ *ការិយាល័យចាត់ថ្នាក់ខ្សែភាពយន្តនិងអក្សរសាស្ត្រ។ អង្គភាពប្រព្រឹត្តខាងការ ចាត់ថ្នាក់* មានអំណាចយកមនុស្ស ឬអង្គការដែលល្មើសច្បាប់ខាងការចាត់ថ្នាក់ទៅកាត់ទោស។

សូមទាក់ទងទៅ *អង្គភាពប្រព្រឹត្តខាងការចាត់ថ្នាក់* បើលោកអ្នកជឿថាមនុស្សម្នាក់ ឬអង្គការ មួយប្រហែលជាប្រព្រឹត្តល្មើសច្បាប់ខាងការចាត់ថ្នាក់៖

- censorship@dia.govt.nz
- 0800 257 887
- www.dia.govt.nz/Services-Censorship-Compliance-Index

**សេវាកម្មគយញូហ្ស៊ីឡែន (New Zealand Customs Service)**

*សេវាកម្មគយញូហ្ស៊ីឡែន* បង្ការមិនឲ្យវត្ថុហាម ចូលពីប្រទេសឯទៀតមកញូហ្ស៊ីឡែនបាន។ សូមទាក់ទងទៅទៅ *សេវាកម្មគយញូហ្ស៊ីឡែន* ៖

- feedback@customs.govt.nz
- 0800 428 786

## នគរបាល (Police)

*នគរបាល* ធ្វើការជាមួយ *សេវាកម្មគយញូហ្ស៊ីឡែន* នឹង *ក្រសួងការក្នុងប្រទេស* ដើម្បីធ្វើឱយ ប្រតិបត្តិច្បាប់ខាងការចាត់ថ្នាក់នៅញូហ្ស៊ីឡែន។ សូមទាក់ទងស្ថានីយនគរបាលនៅតំបន់របស់ លោកអ្នកដើម្បីយកព័ត៌មានបន្ថែម។

## ទាក់ទង *ការិយាល័យចាត់ថ្នាក់ខ្សែភាពយន្តនិងអក្សរសាស្ត្រ*

*ការិយាល័យចាត់ថ្នាក់ខ្សែភាពយន្តនិងអក្សរសាស្ត្រ* ឆ្លើយសំនួរផ្សេងៗអំពីការចាត់ថ្នាក់នៅ ញូហ្ស៊ីឡែន។
សូមទាក់ទង *ការិយាល័យចាត់ថ្នាក់ខ្សែភាពយន្តនិងអក្សរសាស្ត្រ* ៖

- information@censorship.govt.nz
- 0508 236 767